ទំព័រពិត

# សិទ្ធិរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នាមនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ: សំណួរដែលត្រូវបានគេសួរជាញឹកញាប់

FREE & EQUAL
UNITED NATIONS FOR LGBT EQUALITY

## តើពាក្យ "LGBT" មានន័យថាដូចម្តេច?

LGBTមានន័យថា "មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ "។ ស្រប ពេលដែលពាក្យទាំងនេះត្រូវបានទទួលស្គាល់ជាសកលកាន់តែច្រើនក្នុង វប្បធម៌ផ្សេងៗគ្នា ក៏មានការប្រើប្រាស់ពាក្យផ្សេងទៀត ដើម្បីសំដៅទៅ លើ មនុស្សដែលមានទំនាក់ទំនងផ្លូវភេទដូចគ្នា និង មនុស្សដែលមិនមាន អត្តសញ្ញាណយេនឌ័រទ្វិភាព (ដូចជា as *hijra, meti, lala, skesana, motsolle, mithli, kuchu, kawein, travesty, muxe, fa'afafine, fakaleiti, hamjensgara* និង Two-Spirit) ។ ក្នុងបរិបទសិទ្ធិមនុស្ស មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ប្រឈមមុខនូវបញ្ហា ដូចគ្នា និង ខុសគ្នា។ មនុស្សដែលមានភេទពីរ (ដែលកើតមកមានរូបរាង ប្រដាប់ភេទខុសពីធម្មតា) ទទួលបាននូវការរំលោភសិទ្ធិមនុស្សដូចគ្នានឹង មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ដែរ ដែលនឹងបង្ហាញ ខាងក្រោម។

## តើអ្វីជា "ទំនោរផ្លូវភេទ" ?

ទំនោរផ្លូវភេទសំដៅទៅលើការទាក់ទាញផ្លូវកាយ មនោសញ្ចេតនា និង/ឬ ផ្លូវចិត្តរបស់មនុស្សម្នាក់ចំពោះអ្នកដទៃទៀត។ មនុស្សគ្រប់រូបតែងតែមាន ទំនោរផ្លូវភេទ ដែលជាផ្នែកមួយដ៏សំខាន់ចំពោះអត្តសញ្ញាណរបស់ មនុស្ស ម្នាក់។ បុរសស្រលាញ់បុរស និង ស្ត្រីស្រលាញ់ស្ត្រី គឺជាការទាក់ ទាញ ផ្លូវភេទទៅលើបុគ្គលដទៃដែលមានភេទដូចជាពួកគេ។ អ្នក ស្រលាញ់ភេទ ផ្ទុយគ្នា (ជួនកាលត្រូវបានគេហៅថា "មនុស្សត្រង់") មានការទាក់ទាញ លើបុគ្គលដែលមានភេទផ្ទុយគ្នាពីពួកគេ។ មនុស្ស ស្រលាញ់ភេទទាំងពីរ អាចមានការទាក់ទាញទៅលើមនុស្សដែលមាន ភេទដូចគ្នា ឬ ខុសគ្នា។ ទំនោរផ្លូវភេទគឺមិនមានការពាក់ព័ន្ធគ្នាទៅ លើអត្តសញ្ញាណយេនឌ័រទេ។

## តើអ្វី ជា "អត្តសញ្ញាណយេនឌ័រ" ?

អត្តសញ្ញាណយេនឌ័រ ឆ្លុះបញ្ចាំងពីអារម្មណ៍យេនឌ័រដែលបុគ្គលម្នាក់បាន ជួបប្រទះផ្ទាល់ខ្លួន និង មានលក្ខណៈស៊ីជម្រៅ។ អត្តសញ្ញាណយេនឌ័រ របស់មនុស្សម្នាក់ ជាធម្មតាតែងតែនៅស្របជាមួយនឹងភេទដែលខ្លួនមាន តាំងពីកំណើត។ រីឯមនុស្សប្តូរភេទ មានភាពស្របគ្នារវាង អារម្មណ៍ភេទ របស់គេ និង ភេទដែល គេមានតាំងពីកំណើត។ ជួនកាល រាងកាយ កាយវិការរបស់គេ និង អកប្ប កិរិយាដែលបញ្ចេញមកខាងក្រៅអាចមាន ការប៉ះទង្គិចទៅនឹងសេចក្តី សង្ឃឹម របស់សង្គម នៃកាយវិការយេនឌ័រ ជាធម្មនិយម។

## តើពាក្យថា "មនុស្សប្តូរភេទ"មានន័យថាដូចម្តេច?

មនុស្សប្តូរភេទ (ជួនកាលត្រូវបានគេហៅកាត់ថា "trans") ជាកម្រងពាក្យ ដែលត្រូវបានប្រើ ដើម្បីបកស្រាយពីអត្តសញ្ញាណភេទជាច្រើនរួមមាន មនុស្ស ប្តូរភេទបន្ទាប់ពីបានវះកាត់ អ្នកស្លៀកសំលៀកបំពាក់ផ្ទុយពីភេទរបស់ខ្លួន (ជួន កាលត្រូវបានគេហៅថា "មនុស្សស្លៀកពាក់ក្លែងខ្លួនភេទ ផ្ទុយ") មនុស្សដែល ត្រូវបានគេសំគាល់ថាជាមនុស្សភេទទីបី និង អ្នកដែលមានរូបរាង និង អត្តចរិក ខុសពីភេទធម្មតា។ មនុស្សស្រីប្តូរភេទត្រូវបានគេសំគាល់ ថាជាស្រី ប៉ុន្តែត្រូវ បាន ចាត់ថ្នាក់ថា បុរសនៅពេលកើត។ មនុស្សប្រុសប្តូរភេទ ត្រូវបានគេសំគាល់ ថាជាបុរស ប៉ុន្តែត្រូវបានចាត់ថ្នាក់ថា ស្រីនៅពេលកើត។ មនុស្សប្តូរភេទខ្លះ ស្វែងរកការវះកាត់ ឬ ចាក់អ័រម៉ូន ដើម្បីរាងកាយរបស់ខ្លួនស្របតាម អត្តសញ្ញាណ យេនឌ័រ ហើយអ្នកខ្លះក៏រក្សារូបរាងធម្មតា។

## តើអ្វីជា "មនុស្សភេទពីរ" ?

មនុស្សភេទពីរ ជាមនុស្សដែលកើតមកមានកាយវិភាគសាស្ត្រភេទ ប្រដាប់ បន្តពូជ និង/ឬ មានក្រូម៉ូសូម ដែលមិនត្រឹមត្រូវតាមនិយមន័យភេទប្រុស ឬ ស្រី។ នេះអាចបង្ហាញឃើញតាំងតែពីពេលកើត ឬ ក្រោយពីពេលកើត។ មនុស្ស ភេទពីរ អាចត្រូវបានសំគាល់ថាជាមនុស្សប្រុស ស្រី ឬ គ្មានភេទតែ ម្តង។ ស្ថានភាពមនុស្សភេទពីរ គឺមិនមែនជាករណីទំនោរផ្លូវភេទ ឬ អត្តសញ្ញាណ យេនឌ័រ ៖ មនុស្សភេទពីរ អាចជួបប្រទះដូចគ្នាទៅលើទំនោរផ្លូវ ភេទ និង អត្តសញ្ញាណយេនឌ័រ ដូចមនុស្សមិនមែនមានភេទពីរដែរ។

## តើអ្វីជា "ការស្អប់មនុស្សស្រលាញ់ភេទដូចគ្នា និង ការស្អប់មនុស្សប្តូរភេទ?

"ការស្អប់មនុស្សស្រលាញ់ភេទដូចគ្នា" ជាការភ័យខ្លាចដោយគ្មានហេតុផល ការ ស្អប់ខ្ពើម ការទាស់ចិត្តទៅលើ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រ លាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ។ "ការស្អប់ មនុស្សប្តូរភេទ" សំដៅលើការភ័យខ្លាច ការស្អប់ខ្ពើម ឬ ការទាស់ចិត្តទៅលើ មនុស្សប្តូរភេទ។ ដោយហេតុថាពាក្យ ការស្អប់មនុស្សស្រលាញ់ភេទដូចគ្នា ត្រូវ បានកគេយល់យ៉ាងទូលំទូលាយ វាតែងតែប្រើដើម្បីសំដៅទៅលើការភ័យខ្លាច ការស្អប់ខ្ពើម និងការទាស់ចិត្តទៅលើ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្ស ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ជាទូទៅតែម្តង។

UNITED NATIONS
UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## តើក្រុមមនុស្សស្រីស្រលាញ់ភេទដូចគ្នាមនុស្សប្រុសស្រលាញ់ភេទដូចគ្នាមនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ប្រឈមមុខនឹងការរំលោភសិទ្ធបែបណាខ្លះ?

ក្រុមមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ គ្រប់វ័យ និង គ្រប់តំបន់នៅលើពិភពលោកទទួលរងនូវការរំលោភសិទ្ធិ។ ពួកគេត្រូវបានគេវាយប្រហារលើរាងកាយ ចាប់ជំរិត រំលោភសេពសន្ថវៈ និង សម្លាប់។ ជាងភាគបី នៃប្រទេសនៅលើពិភពលោក ពួកគេអាចត្រូវបានចាប់ខ្លួន និង ដាក់ពន្ធនាគា (យ៉ាងហោចណាស់ក៏មាន ប្រទេសប្រាំដែលដាក់ទោសប្រហារជីវិត) សម្រាប់ការទំនាក់ទំនងផ្លូវភេទដូចគ្នា តាមការព្រមព្រៀងជាឯកជន។ រដ្ឋតែង តែបរាជ័យក្នុងការការពារ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុស ស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ អំពី ការរើសអើងនៅក្នុងវិស័យឯកជន រួមទាំងកន្លែងធ្វើការ គេហដ្ឋាន និង មន្ទីរសុខាភិបាល។ កុមារ និង មនុស្សពេញវ័យដែលជាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ក៏ប្រឈមមុខនឹងការគម្រាមកំហែងនៅសាលារៀន ហើយក៏អាចត្រូវបានបណ្តេញចេញដោយឪពុកម្តាយ បង្ខំឲ្យចូលមន្ទីរពេទ្យវិកលចរិក ឬក៏បង្ខំអោយរៀបការ។ មនុស្សប្តូរភេទជារឿយៗ ក៏ត្រូវបានគេ បដិសេធនូវអត្តសញ្ញាណនៅលើក្រដាស់ស្នាម ដែលឆ្លុះបញ្ជាំងអំពីភេទរបស់គេ ប្រសិនបើគ្មានក្រដាសអត្តសញ្ញាណទាំងនោះ ពួកគេមិនអាចធ្វើការ ធ្វើដំណើរ បើកគណនី ធនាគារ ឬ ទទួលបានសេវាផ្សេងៗឡើយ។ កុមារដែលមានភេទពីរ ក៏អាចទទួលរងការវះកាត់វេជ្ជសាស្ត្រ និង ការអន្តរាគមន៍ដទៃ ទៀត ដោយគ្មានការយល់ព្រមជាមុនរបស់គេ ឬ ឪពុកម្តាយរបស់គេ ហើយបើជានីតិជនក៏ងាយទទួលរងអំពើហិង្សា និង ការរើសអើងដែរ។

## តើមានហេតុផលណាមួយដើម្បីចាត់ទុកការស្រលាញ់ភេទដូចគ្នាជាបទល្មើសដែរឬទេ?

គ្មានទេ។ ការចាត់ទុកជាបទល្មើសចំពោះទំនាក់ទំនងផ្លូវភេទជាឯកជនរវាង នីតិជនដែលមានការយល់ព្រម ទោះបីជាការទំនាក់ទំនងភេទដូចគ្នាឬផ្ទុយគ្នា ក៏ដោយ គឺជាការរំលោភសិទ្ធិឯកជន។ ច្បាប់ដែលកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះទំនាក់ទំនងផ្លូវភេទ ដោយមានការយល់ព្រមរវាងនីតិជនដែលមានភេទដូចគ្នា គឺជាការរើសអើង ហើយនៅពេលណាច្បាប់នោះត្រូវបានគេអនុវត្ត នោះគឺជាការរំលោភបំពាន ទៅលើសិទ្ធសេរីភាពរួចផុតពីការចាប់ខ្លួន និង ឃុំឃាំងដោយបំពាន។ យ៉ាងហោចណាស់មានប្រទេសចំនួន ៧៦ មានច្បាប់ជាធរមាន ដែលចាត់ទុកជាបទល្មើសចំពោះ ទំនាកទំនងផ្លូវភេទ ដោយមានការព្រមព្រៀងជាឯកជន ហើយក៏នៅមានប្រទេស ៥ ទៀតដែលដាក់ទោសប្រហារជីវិត។ បន្ថែមពីលើការរំលោភសិទ្ធិជាមូលដ្ឋាន ការចាត់ទុកជាបទល្មើសបែបនេះ ជាការធ្វើឲ្យស្របច្បាប់ទៅលើកាយវិការអរិភាពចំពោះ ក្រុម មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ និង ជំរុញអោយកាន់តែមានអំពើហិង្សា និង ការរើសអើង។ វាក៏ជាការរារាំង ដល់កិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ឈប់ ការរីករាលដាលមេរោគអេដស៍ ដោយធ្វើឲ្យ មនុស្សស្រីស្រលាញ់ភេទដូច គ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំង ពីរ និង មនុស្សប្តូរភេទ មានការញញើតចេញមុខមកទទួលយកការធ្វើតេស្ត៍ និង ព្យាបាល ដោយការភ័យខ្លាច ឬ ការបង្ហាញពីសកម្មភាពឧក្រិដ្ឋ។

## តើមនុស្សស្រីស្រលាញ់ភេទដូចគ្នាមនុស្សប្រុសស្រលាញ់ភេទដូចគ្នាមនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទមានតែនៅក្នុងប្រទេសលោកខាងលិចឬ?

ទេ។ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ មាននៅគ្រប់ទីកន្លែង គ្រប់ប្រទេសក្នុងចំណោមជនជាតិភាគតិច គ្រប់ថ្នាក់សង្គមសេដ្ឋកិច្ច និង គ្រប់សហគមន៍ទាំងអស់។ ការអះអាងដែលថា ការទាក់ទាញទៅលើមនុស្សភេទដូចគ្នា គឺជាការប្រព្រឹត្តិរបស់ប្រទេសលោកខាងលិច ជាការខុសឆ្គងហើយ។ ប៉ុន្តែ ពេលបច្ចុប្បន្ននេះមានច្បាប់ព្រហ្មទណ្ឌជាច្រើនត្រូវបានប្រើប្រាស់សម្រាប់ដាក់ទោស មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ គឺមានប្រភពមកពីប្រទេសលោកខាងលិច។ មានករណីជាច្រើនទៀត ត្រូវបានកំណត់លើប្រទេសនាសតវត្សទី ១៩ ដែលត្រូវបានទទួលរងអាណានិគមពីមុនមក។

## តើមនុស្សស្រីស្រលាញ់ភេទដូចគ្នាមនុស្សប្រុសស្រលាញ់ភេទដូចគ្នាមនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទមានតែងតែមានដែរឬទេ?

មាន។ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ តែងតែជាផ្នែកមួយនៃសហគមន៍របស់យើង។ មានឧទាហរណ៍ជាច្រើន មកពីតំបន់នានា និង អំឡុងពេល មកពីគំនូរលើថ្មយុគសម័យមុនបុរេប្រវត្តិ នៅអាហ្វ្រិកខាងត្បូង និង ប្រទេសអេស៊្បែ រហូតដល់មាន អត្ថបទវិជ្ជសាស្ត្រឥណ្ឌាសម័យបុរាណ និង អក្សរសាស្ត្រអូតូមេន ។ មានសង្គមជាច្រើនបើកចំហជាប្រពៃណី ចំពោះ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ រួមមាន សង្គមអាស៊ីដែលមានប្រពៃណីទទួលស្គាល់មនុស្សភេទទីបី។

## តើអាចផ្លាស់ប្តូរទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់មនុស្សម្នាក់បានដែរឬទេ?

អត់ទេ។ ទំនោរផ្លូវភេទ និង /ឬអត្តសញ្ញាណយេនឌ័ររបស់មនុស្សម្នាក់ មិនអាចប្តូរបានទេ។ អ្វីដែលត្រូវផ្លាស់ប្តូរ គឺឥរិយាបថសង្គមជាអវិជ្ជមាន ដែលបង្កស្លាកស្នាមទុរយស៍ ដល់ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ហើយបណ្តាលអោយមានអំពើហិង្សា និង ការរើសអើងទៅលើពួកគេ។ ការប៉ុនប៉ងក្នុងការផ្លាស់ប្តូរទំនោរផ្លូវភេទ តែងតែពាក់ព័ន្ធទៅនឹងការរំលោភសិទ្ធិ ហើយអាចបង្កអោយមានការប៉ះពាល់ផ្នែកសតិអារម្មណ៏ ធ្ងន់ធ្ងរ។ ឧទាហរណ៍ រួមមានការបង្ខំការព្យាបាលសរសៃប្រសាទ ក្នុងគោលបំណង "ព្យាបាល" បុគ្គលដែលមានការទាក់ទាញលើភេទដូចគ្នា និង ការរំលោភសេពសន្ថវៈ "កែតម្រូវ" លើមនុស្សស្រីស្រលាញ់ស្រីដូចគ្នា ដោយការប្រកាសពីបំណងដើម្បីអោយពួកគេ"ប្តូរចិត្តមកស្រលាញ់ភេទផ្ទុយគ្នា" វិញ។

## តើការរស់នៅក្បែរមនុស្សស្រីស្រលាញ់ភេទដូចគ្នាមនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ឬ ការមានសិទ្ធិទទួលបានព័ត៌មានអំពីការស្រលាញ់ភេទដូចគ្នា ធ្វើអោយប៉ះពាល់ដល់សុខុមាលភាពរបស់កុមារដែរឬទេ?

ទេ។ ការស្វែងយល់ពី ឬ ការចំណាយពេលជាមួយ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ មិនបានធ្វើអោយមានការប៉ះពាល់ដល់ទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័ររបស់អនីតិជន ហើយក៏មិនធ្វើអោយមានការប៉ះពាល់ដល់សុខុមាលភាពរបស់ពួកគេទេ។ ប៉ុន្តែ វាជាកាសំខាន់ដែលយុវជនគ្រប់រូប ទទួលបានការអប់រំអំពីផ្លូវភេទដែលសមរម្យ ទៅតាមអាយុរបស់គេ ដើម្បីធានាថា ពួកគេមានសុខភាពល្អ ទទួលបានទំនាក់ទំនងផ្លូវកាយដោយថ្លៃថ្នូរ ហើយអាចការពារខ្លួនគេ ពីការចម្លងរោគតាមផ្លូវភេទ។

## តើមនុស្សប្រុសស្រលាញ់ប្រុសដូចគ្នាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរឬ មនុស្សប្តូរភេទ មានគ្រោះថ្នាក់ចំពោះកុមារដែរឬទេ ?

ទេ។ គ្មានការទាក់ទងរវាងការស្រលាញ់ភេទដូចគ្នា និង ការរំលោភបំពានណាមួយទៅលើកុមារទេ។ មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទទាំងអស់នៅលើពិភពលោក អាចជាឪពុកម្តាយ គ្រូបង្រៀន និង មនុស្សគួរអោយស្ញើចសរសើរដ៏ល្អសម្រាប់កុមារ។ ការង្ហាញថា មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទ ជា "មនុស្សដែលមានអារម្មណ៍ផ្លូវភេទជាមួយកុមារ" ឬ ជាមនុស្សគ្រោះថ្នាក់ចំពោះកុមារ គឺមិនត្រឹមត្រូវទាំងស្រុងជាកាប្រមាថ និង ជាការបំបែកចេញពីតម្រូវការចាត់វិធានការសមស្រប និង ម៉ឺងម៉ាត់ សម្រាប់ការពារកុមារគ្រប់រូប រួមទាំងកុមារដែលដឹងអំពីទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័ររបស់គេ។

## តើច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុវត្តចំពោមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ប្រុសដូចគ្នាមនុស្សស្រលាញ់ភេទទាំងពីរ និង មនុស្សប្តូរភេទដែរឬទេ ?

បាទ ចាស ច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុវត្តចំពោះមនុស្សគ្រប់រូប។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ បង្កើត កាតព្វកិច្ចតាមផ្លូវច្បាប់ដល់រដ្ឋ ដើម្បីធានាថា មនុស្សគ្រប់រូប អាចទទួលបានសិទ្ធិមនុស្សរបស់ខ្លួន ដោយមិនមានភាពខុសគ្នា ។ ទំនោរផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ របស់មនុស្សម្នាក់ គឺជាស្ថានភាពមួយដែរ គឺជាតិសាសន៍ ភេទ ពណ៌សម្បុរ ឬ សាសនា។ អ្នកជំនាញការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ថា ច្បាប់អន្តរជាតិ ហាមឃាត់ការរើសអើង ដោយសារទំនោរផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ។

## តើការដកហូតសិទ្ធមនុស្សរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ប្រុសដូចគ្នាមនុស្សស្រលាញ់ភេទទាំងពីរនិង មនុស្សប្តូរភេទ អាចធ្វើឡើងដោយសមហេតុផលដែរឬទេ ដោយសារកត្តាសាសនា វប្បធម៌ ឬ ប្រពៃណីទេ?

ទេ សិទ្ធិមនុស្សគឺមានជាសកល: មនុស្សគ្រប់រូបគឺទទួលបានសិទ្ធិដូចគ្នា មិនថាពួកគេជានរណា ឬ រស់នៅទីណាទេ។ ស្របពេលដែលប្រវត្តិសាស្រ្ត វប្បធម៌ សាសនា សុទ្ធតែសំខាន់តាមបរិបទ រដ្ឋទាំងអស់ មិនថាមានប្រព័ន្ធនយោបាយ សេដ្ឋកិច្ច និង វប្បធម៌យ៉ាងណានោះទេ សុទ្ធតែមានករណីយកិច្ចផ្លូវច្បាប់ក្នុងការលើកកម្ពស់ និង ការពារសិទ្ធិមនុស្សគ្រប់រូប។